01215705
Declassified to Public
12 June 2020



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
Office of the Co-Investigating Judges
Bureau des co-juges d'instruction

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 22 / 03 / 2016
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SAMN RADA

សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត
កាលបរិច្ឆេទ ៖ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦
ភាសា ៖ អង់គ្លេស [ភាសាដើម]
ចំណាត់ថ្នាក់ឯកសារ ៖ សម្ងាត់

# ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបន្ទាប់ឲ្យអង្គភាពគាំពារការការពារក្តីផ្តល់ធនធានបន្ថែម

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តីអោ អាន**
មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តីយឹម ទិត្យ**
សូ មូស្សេទ្ធី
Suzana TOMANOVIĆ

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីនៃ
ទី ស្រីនណា
វ៉ែន ពៅ
Linda BEHNKE
Laure DESFORGES NZEPA
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

**អង្គភាពគាំពារការការពារក្តី**

**ការិយាល័យរដ្ឋបាល**

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥ អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon បានដាក់ អោ អាន ឱ្យស្ថិតក្រោមការពិនិត្យពីបទល្មើសនៃការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលចោទថាបានប្រព្រឹត្តឡើងនៅទីតាំងផ្សេងគ្នាចំនួនបីកន្លែងនៅភូមិភាគកណ្ដាល នៃកម្ពុជាប្រជាធិបតេយ្យ[1]។ ចៅក្រម Harmon ក៏បានជូនដំណឹង អោ អាន ថា គាត់ក៏ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋមួយចំនួនក្នុងចំណោមបទឧក្រិដ្ឋទាំងនេះ *ជាអាទិ៍* តាមរយៈការចូលរួមសហឧក្រិដ្ឋកម្មរួម("ការបង្ហាញខ្លួនលើកដំបូង")[2]។

២. នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ ខ្ញុំបានជូនដំណឹង អោ អាន ថា មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា គាត់អាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅទីតាំងដប់កន្លែងបន្ថែមទៀតនៅភូមិភាគកណ្ដាល។ បទចោទប្រកាន់ថ្មីទាំងនេះ រួមមាន អំពើប្រល័យពូជសាសន៍ ដែលពីមុនមិនបានដាក់ឱ្យស្ថិតក្រោមការពិនិត្យទេ និងសហឧក្រិដ្ឋកម្មរួមដែលមានវិសាលភាពធំជាងសហឧក្រិដ្ឋកម្មរួមដែលពីមុនបានដាក់ឱ្យស្ថិតក្រោមការពិនិត្យ ("បទចោទប្រកាន់បន្ថែម")[3]។ ស្របតាមផែនការបញ្ចប់ការងាររបស់ អ.វ.ត.ក ចុះផ្សាយនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ កិច្ចស៊ើបសួរលើ អោ អាន គ្រោងនឹងបិទនៅត្រឹមខែ មិថុនា ឆ្នាំ ២០១៦។

៣. នៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ មេធាវីការពារក្ដី អោ អាន បានដាក់ *សំណើបន្ទាន់សុំធនធានបន្ថែម* ដែលក្នុងសំណើនេះ មេធាវីការពារក្ដី បានជូនដំណឹងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") ថា នៅពេលដែលមានការជូនដំណឹងអំពីបទចោទប្រកាន់បន្ថែម និងគោលបំណងបិទកិច្ចស៊ើបសួរនៅត្រឹមខែ មិថុនា ឆ្នាំ ២០១៦ រួចមក មេធាវីការពារក្ដី បានស្នើអង្គភាពគាំពារការការពារក្ដី("អ.គ.ក") សុំធនធានបន្ថែមដើម្បីដោះស្រាយបន្ទុកការងារ

---

[1]សំណុំរឿង ០០៤ ឯកសារ D242 *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង* ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០១៥ ទំព័រ ១០។

[2]*ដូចដើងទំព័រខាងលើ* ទំព័រ ១១។

[3]សំណុំរឿង ០០៤ ឯកសារ D303 *កំណត់ហេតុនៃការបង្ហាញខ្លួនម្ដងទៀត* ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ២០១៦ ទំព័រ ៨-៩ [ភាសាអង់គ្លេស]។

01215707



បន្ថែម(“សំណើសុំធនធាន”)[4]។ យោងតាមមេធាវីការពារក្ដី ប្រធាន អ.គ.ក បានបដិសេធសំណើនេះ ពីព្រោះថា មិនមានថវិកានៅសល់នៅក្នុងថវិការបស់មេធាវីការពារក្ដី សម្រាប់ឆ្នាំ ២០១៦ ទេ ប៉ុន្តែ បានបញ្ជាក់ថា គាត់អាចស្វែងរកធនធានបន្ថែមទៀតប្រសិនបើទទួលបានការណែនាំពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ឱ្យធ្វើដូច្នេះ[5]។

៤. មេធាវីការពារក្ដី អះអាងថា ដើម្បីឱ្យមានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ដើម្បីការពារក្ដី អោ អាន មេធាវីការពារក្ដី ត្រូវការបុគ្គលិកបន្ថែមទៀតដើម្បីជួយរៀបចំសំណើសុំបំពេញកិច្ចស៊ើបសួរ ឬពាក្យសុំមោឃភាពកិច្ចស៊ើបសួរ ដែលអាចចាំបាច់ ដោយសារមានបទចោទប្រកាន់បន្ថែម[6]។

៥. អាស្រ័យហេតុនេះ មេធាវីការពារក្ដី ស្នើ ស.ច.ស បង្គាប់ឱ្យ អ.គ.ក បង្កើនថវិការបស់មេធាវីការពារក្ដី ដើម្បីឱ្យអាចជ្រើសរើសអ្នកប្រឹក្សាច្បាប់អន្តរជាតិជាន់ខ្ពស់ម្នាក់ក្នុងតំណែងកម្រិត ៤ និងអ្នកប្រឹក្សាច្បាប់អន្តរជាតិកម្រិតទាបម្នាក់ក្នុងតំណែងកម្រិត ២ ហើយ បង្គាប់ឱ្យការិយាល័យរដ្ឋបាល ផ្ដល់ការគាំទ្រចាំបាច់ទាំងអស់ដើម្បីសម្របសម្រួលការជ្រើសរើសទាំងនេះ[7]។

## II. ពិភាក្សា

### ក. សិទ្ធិអំណាចរបស់ ស.ច.ស ដើម្បីត្រួតពិនិត្យសេចក្ដីសម្រេចរបស់ អ.គ.ក

៦. មាត្រា ២៣(ថ្មី)នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ឱ្យ ស.ច.ស ទទួលខុសត្រូវលើកិច្ចស៊ើបសួររបស់តុលាការ។ ការទទួលខុសត្រូវនេះ រួមមានការធានាឱ្យមានយុត្តិធម៌នៅក្នុងដំណើរការនីតិវិធី[8]។ ការទទួលខុសត្រូវនេះគឺជាផ្នែកចាំបាច់នៃការងាររបស់ ស.ច.ស ប៉ុន្តែ វិធានផ្ទៃក្នុងមិនបានចែងច្បាស់ផ្ដល់ជូន ស.ច.ស នូវសិទ្ធិអំណាចត្រួតពិនិត្យសេចក្ដីសម្រេចរបស់ អ.គ.ក លើសំណើសុំធនធានពីសំណាក់ជនត្រូវចោទនៅក្នុងអំឡុងពេលបំពេញកិច្ចស៊ើបសួរទេ។ ហេតុ

---

[4]សំណុំរឿង ០០៤ ឯកសារ D304 *សំណើបន្ទាន់សុំធនធានបន្ថែម* ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០១៦ កថាខណ្ឌ ៣ និង១៣។

[5]*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៤ ។

[6]*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៥។

[7]*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៨។

[8]*សូមមើល* វិធានផ្ទៃក្នុង ២១(១)(ក)។

នេះ យោងតាមមាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ខ្ញុំយល់ឃើញថាជាការសមស្របដែលត្រូវស្វែងរកការណែនាំផ្នែកនីតិវិធីពាក់ព័ន្ធដែលបានបង្កើតឡើងរួចហើយនៅកម្រិតអន្តរជាតិ។

៧. មានមូលដ្ឋានគ្រឹះរឹងមាំនៅកម្រិតអន្តរជាតិដែលថា អង្គភាពតុលាការមានអំណាចមានស្រាប់ដើម្បីសម្រេចលើបញ្ហាចៃដន្យ ដែលកើតឡើងផ្ទាល់ដោយសារការអនុវត្តយុត្តាធិការចម្បងរបស់ខ្លួន[9]។ អំណាចមានស្រាប់ទាំងនេះ រួមមាន សិទ្ធិអំណាចត្រួតពិនិត្យសេចក្តីសម្រេចរដ្ឋបាលដែលអាចប៉ះពាល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជន ដែលត្រូវ ចោទពីបទឧក្រិដ្ឋណាមួយ[10]។ ប៉ុន្តែ វិធានការឯកតោភាគីបែបនេះរបស់តុលាការ តទល់នឹងរដ្ឋបាលដែលជាអ្នកកាន់កាប់ថវិកា គប្បីធ្វើឡើងតែក្នុងជម្រើសមួយចុងក្រោយបំផុតតែប៉ុណ្ណោះ។ ខ្ញុំបានពិគ្រោះយោបល់ជាមួយនឹងអនុប្រធានរដ្ឋបាលនៅជំនួយការអង្គការសហប្រជាជាតិសម្រាប់ការជំនុំជម្រះខ្មែរក្រហម(UNAKRT) ហើយទទួលបានការធានាថា ប្រសិនបើខ្ញុំសម្រេចថា សំណើរបស់មេធាវីការពារក្តី មានមូលដ្ឋាន នោះនឹងមានកិច្ចខិតខំប្រឹងប្រែងដើម្បីទទួលបានដំណោះស្រាយឲ្យបានគ្រប់គ្រាន់។

## ខ. សំណើរបស់មេធាវីការពារក្តី សុំធនធានបន្ថែម

៨. សិទ្ធិទទួលបានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី ដែលមានចែងនៅក្នុងមាត្រា ១៤(៣)(ខ)នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គឺជាធាតុ

[9]សំណុំរឿង ០០២ ឯកសារ D14/1/2 *ដីកាសម្រេចព្យួរការអនុវត្ត"ដីកាសម្រេចស្តីពីសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣"* ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៤។ តុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Mejakić និងអ្នកផ្សេងទៀត* ឯកសារសំណុំរឿង IT-02-65-AR73.1 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា ដើម្បីដោះស្រាយទំនាស់ផលប្រយោជន៍ ទាក់ទងនឹងមេធាវី Goran Simić* ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៤ កថាខណ្ឌ ៧។

[10]*សូមមើល* រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Šešelj* ឯកសារសំណុំរឿង IT-03-67-R33B *សាធារណៈ សំណៅកោសលុបនៃសេចក្តីសម្រេចលើសារណារដ្ឋបាល យោងតាមវិធាន ៣៣(ខ)ទាក់ងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការផ្តល់ថវិកាសម្រាប់មេធាវីការពារក្តី ដែលធ្វើឡើងចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១១* ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១១ កថាខណ្ឌ ១៩-២០។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Karadžić* ឯកសារសំណុំរឿង IT-95-5/18-PT *សេចក្តីសម្រេចលើញត្តិរបស់ជនជាប់ចោទ សុំសម្ភារៈរូបវន្តគ្រប់គ្រាន់ និងសមភាពនៃមធ្យោបាយតទល់ក្តី៖ មន្ត្រីច្បាប់រង* ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៩ កថាខណ្ឌ ១២។

ផ្សំមួយជាសារវន្តនៃការធានាឱ្យមានការជំនុំជម្រះដោយយុត្តិធម៌ និងជាផ្នែកមួយចាំបាច់នៃគោលការណ៍សមភាពនៃមធ្យោបាយតទល់ក្តី[11]។ អ្វីដែលជា"ពេលវេលាគ្រប់គ្រាន់"គឺអាស្រ័យតាមកាលៈទេសៈករណីនីមួយៗ[12]។

៩. នៅក្នុងកាលៈទេសៈករណីបច្ចុប្បន្ននេះ ខ្ញុំយល់ឃើញថាមានការពាក់ព័ន្ធត្រង់ថា អោ អាន ត្រូវបានជូនដំណឹងអំពីបទចោទប្រកាន់បន្ថែមចំនួនដ៏ច្រើននៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ សហឧក្រិដ្ឋកម្មរួមដែលគាត់ត្រូវបានចោទជាសមាជិកម្នាក់ដែលបានចូលរួម គឺមានវិសាលភាពធំជាងវិសាលភាពនៃសហឧក្រិដ្ឋកម្មរួមដែលបានជូនដំណឹងគាត់នៅក្នុងអំឡុងពេលបង្ហាញខ្លួនលើកដំបូង ហើយកិច្ចស៊ើបសួរលើ អោ អាន គ្រោងនឹងបញ្ចប់នៅខែ មិថុនា ឆ្នាំ ២០១៦ យោងតាមផែនការបញ្ចប់ការងាររបស់ អ.វ.ត.ក ចុះផ្សាយនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥។ ខ្ញុំក៏សម្គាល់លើការអះអាងរបស់មេធាវីការពារក្តី ដែលថា ដើម្បីឱ្យអាចធ្វើសំណើសុំបំពេញកិច្ចស៊ើបសួរ និងសំណើប្រភេទផ្សេងទៀតទាក់ទងនឹងបទចោទប្រកាន់បន្ថែមតាមកាលបរិច្ឆេទនោះ មេធាវីការពារក្តី ត្រូវការអ្នកប្រឹក្សាច្បាប់អន្តរជាតិពីររូបបន្ថែមទៀត។

១០. ជាគោលការណ៍ ខ្ញុំយល់តាមសំណើនេះ និងផ្តល់ការគាំទ្រជាទូទៅចំពោះសំណើនេះ ប៉ុន្តែបច្ចុប្បន្ននេះ យុត្តិកម្មសម្រាប់សុំបុគ្គលិកបន្ថែម គឺមិនមានភស្តុតាងបញ្ជាក់គ្រប់គ្រាន់។ ខ្ញុំកត់សម្គាល់ថា អោ អាន មានសហមេធាវីរូបបី ដែលនេះគឺជាករណីពិសេសនៅក្នុងចំណោមក្រុមការងារមេធាវីការពារក្តី នៅ អ.វ.ត.ក។ ហើយក៏មិនច្បាស់ថាតើហេតុអ្វីបានជាចាំបាច់ត្រូវការសមាជិកថ្មីពីរនាក់ទៀត ដោយម្នាក់ជាអ្នកប្រឹក្សាជាន់ខ្ពស់។ ខ្ញុំនឹងត្រូវការព័ត៌មានលម្អិតថែមទៀត និងប្រសើរជាងនេះមុនពេលខ្ញុំអាចសម្រេចបាន។

១១. ដីកាសម្រេចនេះដាក់ជាភាសាអង់គ្លេសដោយឯកសារបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។

---

[11] *សូមមើល* គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីជូនដំណឹងលេខ ២៨២/១៩៨៨ រឿងក្តី *Smith តទល់នឹងប្រទេស Jamaica* កថាខណ្ឌ ១០.៤។

[12] *សូមមើល* គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីជូនដំណឹងលេខ ៣៤៩/១៩៨៩ រឿងក្តី *Wright តទល់នឹងប្រទេស Jamaica* កថាខណ្ឌ ៨.៤។

**តាមសំអាងហេតុខាងលើ ខ្ញុំ ៖**

១២. **បង្គាប់** មេធាវីការពារក្តី ក្នុងរយៈពេលមួយសប្តាហ៍បន្ទាប់ពីមានការជូនដំណឹងអំពីដីកាសម្រេចនេះ ត្រូវផ្តល់ព័ត៌មានលម្អិតថែមទៀត និងប្រសើរជាងនេះអំពីយុត្តិកម្មសម្រាប់សុំតំណែងទាំងពីរនេះ។

១៣. **បង្គាប់** មេធាវីការពារក្តី ត្រូវបញ្ចូល អ.គ.ក និងការិយាល័យរដ្ឋបាល ចូលក្នុងចំណោមអ្នកទទួលឯកសារ។

១៤. **ស្នើ** អ.គ.ក និងការិយាល័យរដ្ឋបាល ត្រូវដាក់ចម្លើយតបដែលខ្លួនអាចមានទៅនឹងសារណាបន្ថែមទៀតរបស់មេធាវីការពារក្តី ក្នុងរយៈពេលមួយសប្តាហ៍បន្ទាប់ពីមានការជូនដំណឹងអំពីសារណាទាំងនោះ។

១៥. នៅទទួលពិនិត្យបញ្ហានេះ។

ភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**